00475528

ឯកសារ:D345/2

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១០

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 15 / 02 / 2010
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**សំណើលោក អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក**

**ដាក់ដោយ៖**

**សហមេធាវី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“សហមេធាវីការពារក្តី”) អនុលោមតាម វិធានផ្ទៃក្នុង ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធាន”) សូមដាក់សំណើប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក។ សំណើនេះមានភាពចាំបាច់ពីព្រោះ៖ ក) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាទម្រង់មួយនៃការទទួលខុសត្រូវ ដែលទទួលស្គាល់នៅក្នុងច្បាប់កម្ពុជា ខ) ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាផ្នែកមួយនៃទម្លាប់អន្តរជាតិនៅពេលវេលាដ៏សមស្របមួយ[1] និងគ) ទោះបីជា អ.វ.ត.ក អាចអនុវត្តទម្លាប់អន្តរជាតិក៏ដោយ ហើយការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាផ្នែកមួយនៃទម្លាប់អន្តរជាតិនៅពេលនោះក៏ដោយ ក៏ការអនុវត្តរបស់ខ្លួននឹងរំលោភលើគោលការណ៍គ្មានច្បាប់គឺគ្មានទោស (*nullum crimen sine lege*)។

## I. ការទទួលយកបាននៃសំណើនេះ

១. វិធាន ៥៥(១០) អនុញ្ញាតិឲ្យភាគីស្នើសុំឲ្យ កសចស ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ឬចាំបាច់ដល់ការស៊ើបសួរ[2]។ ក.ស.ច.ស បានបញ្ជាក់ពីមុនថា សំណើសុំរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.កជាទម្រង់នៃការទទួលខុសត្រូវ

---

[1] មេធាវីការពារក្តីរក្សាទស្សនៈទានដែលបានលើកឡើងកាលពីលើកមុនរបស់ខ្លួន ថា អ.វ.ត.ក មិនអាចអនុវត្ត ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ។ ទឡ្ហីករណ៍នេះនឹងមិនត្រូវបានថ្លែងនៅក្នុងនេះទេ ដោយសារមិនមានទំព័រគ្រប់គ្រាន់ដើម្បីធ្វើសំណើរនេះ។ ចំពោះការពន្យល់នៃមូលហេតុដែលថា អ.វ.ត.ក មិនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលដែលត្រូវបានស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០, ឯកសារ D97/14/5, ERN: 00429213-00429253 (“បណ្តឹងឧទ្ធរណ៍ JCE”), កថាខណ្ឌ ២៥-៣៥។ *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩, ឯកសារ D240, ERN: 00401925-00401940 (“សំណើទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍”), កថាខណ្ឌ១៧-២០, ២៥-៣០។

[2] ក.ស.ច.ស បានកត់សម្គាល់ថា មិនដូចវិធានផ្ទៃក្នុងផ្នែកជាភាសាអង់គ្លេស ដែលតម្រូវថាដីកាដែលត្រូវបានស្នើ ឬកិច្ចស៊ើបសួរត្រូវតែ “ចាំបាច់” ផ្នែកជាភាសាបារាំងគ្រាន់តែចែងថាវាត្រូវតែ “មានប្រយោជន៍”។ *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D97/13, ERN: 00411047-00411056, ជើងទំព័រ២៣ (“ដីកា JCE”)។

ដែលត្រូវបានគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម (សំណើសុំ JCE)[3] គួរត្រូវបានពិចារណាឱ្យបានសមស្របនៅក្រោមវិធាន ៥៥(១០)[4]។ សំណើសុំបច្ចុប្បន្នស្រដៀងនឹងសំណើសុំ JCE ៖ សំណើសុំនេះស្នើថា ទម្រង់នៃការទទួលខុសត្រូវដែលមិនមានចែងនៅក្នុងច្បាប់កម្ពុជា និងមិនមាននៅក្នុងទម្លាប់អន្តរជាតិនៅពេលវេលាដ៏សមស្របមួយមិនអាចអនុវត្តនៅ អ.វ.ត.ក បាននោះទេ។ មិនដូចសហឧក្រិដ្ឋកម្មរួមដែលមិនបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់បង្កើត អ.វ.ត.ក ថា ការទទួលខុសត្រូវរបស់ថ្នាក់លើ មានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក។ ទោះយ៉ាងនេះក៏ដោយ សំណើសុំបច្ចុប្បន្ន មិនបានស្នើសុំស្រាយច្បាប់នោះទេ[5]។

២. ក្នុងការពិភាក្សាអំពីការអនុវត្តបទល្មើសប្រល័យពូជសាសន៍នៅ អ.វ.ត.ក ក.ស.ច.ស បានបញ្ជាក់ថា វាមិនចាំបាច់ក្នុងការកំណត់អង្គច្បាប់ស្ថាពររហូតដល់ដីកាដំណោះស្រាយចេញសិន[6]។ បញ្ហាដែលថាតើ ក.ស.ច.ស អាចអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវតែសម្រេចនៅក្នុងដំណាក់កាលនេះនៅក្នុងដំណើរការនីតិវិធីនេះឬក៏អត់។ លោក អៀង សារី ត្រូវតែបានដឹងអំពីទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តប្រឆាំងរូបគាត់។ សហមេធាវីការពារក្តីមានកាតព្វកិច្ចប្តឹងឧទ្ធរណ៍

---

[3] *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យស្នើសុំរបស់លោកអៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្ម រួម, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ D97។

[4] ដីកា JCE, កថាខណ្ឌ ៨។

[5] នៅពេលដែលមេធាវីបានស្នើថា ក.ស.ច.ស ចេញដីកាមួយស្តីពីលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅ អ.វ.ត.ក ការិយាល័យសហចៅក្រមស៊ើបអង្កេតបានថ្លែងថា មេធាវីការពារក្តីបានស្នើសុំកាស្រាយច្បាប់ពាក់ព័ន្ធនឹងការអនុវត្តច្បាប់នោះ និង កង្វល់នៃការជូនដំណឹងសមស្របដែលផ្តល់ជូនជនត្រូវចោទ មិនពាក់ព័ន្ធនឹងបញ្ហាដូចជា អំពើប្រល័យពូជសាសន៍ ដូចដែលត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីកាបង្កើត អ.វ.ត.ក"), និង កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។ *រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរនៅលើលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ, D240/3, ERN: 00421137-00421140, កថាខណ្ឌ៣។ ក.ស.ច.ស បានថ្លែងថា ខ្លួនមិនបានតម្រូវអោយបញ្ជាក់អំពីការកំណត់ប្រភេទបទល្មើសស្ថាពរឡើយ រហូតដល់មានដីកាដំណោះស្រាយ។ ហើយថាដូច្នេះនៅក្នុងដំណាក់កាលនេះមិនចាំបាច់ធ្វើការវិភាគបញ្ហានេះឱ្យពេញលេញនោះទេ។ *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៤។

[6] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៤។

ប្រឆាំងនឹងដីកាទាំងឡាយដែលបញ្ជាក់អះអាងយុត្តាធិការរបស់ អ.វ.ត.ក។ សិទ្ធិប្តឹងឧទ្ធរណ៍នេះនឹងលែងមានន័យ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតិឲ្យលើកឡើងអំពីបញ្ហានៃ យុត្តាធិការចំពោះ ក.ស.ច.ស ទេនោះ។

## II. ច្បាប់ដែលយកមកអនុវត្ត

៣. មាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក មួយផ្នែកចែងថា:

> ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣ថ្មី ៤, ៥, ៦, ៧ និង មាត្រា ៨នៃច្បាប់នេះត្រូវបាន ប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនេះ។

## III. ទឡ្ហីករណ៍

### ក. ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលទទួលស្គាល់នៅក្នុងច្បាប់កម្ពុជានោះទេ

៤. ក្នុងនាមជាតុលាការកម្ពុជាមួយ អ.វ.ត.ក មានកាតព្វកិច្ចអនុវត្តតាមច្បាប់កម្ពុជា[7]។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រមព្រហ្មទណ្ឌដែលនៅជាធរមាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ គឺជាពេលវេលាមួយដែលតាមការចោទប្រកាន់ថាបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តធ្វើឡើង[8]។ ការទទួលខុសត្រូវរបស់ថ្នាក់លើមិនត្រូវបានរកឃើញនៅក្នុងក្រម

---

[7] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១២(១)។ *សូមមើលផងដែរ* បុព្វកថានៃវិធានផ្ទៃក្នុង, វិសោធនកម្មទី៤, ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។

[8] *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ព័ត៌មានអំពីក្រមព្រហ្មទណ្ឌ ១៩៥៦ របស់ប្រទេសកម្ពុជានិង សំណើសុំផ្តល់ការបញ្ជាក់លើក្រមផ្លូវការ, ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩, ឯកសារ E91/5, ERN: 00365471-00365472។

ព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះទេ។ ច្បាប់បង្កើត អ.វ.ត.ក មិនបានបង្កើតច្បាប់សារធាតុព្រហ្មទណ្ឌជាតិថ្មីមួយនោះទេ[9]។ ដូចនេះ ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនឹងរំលោភលើ *គោលការណ៍គ្មានច្បាប់គ្មានបទល្មើស (nullum crimen sine lege)*។

**ខ. ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមែនជាផ្នែកមួយនៃទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ**

៥. ទម្លាប់អន្តរជាតិអាចអនុវត្តបានតែតាមរយៈ (ក) ការអនុវត្តជាទូទៅ និងស៊ីសង្វាក់របស់រដ្ឋដែលសំដែងឱ្យឃើញថា (ខ) *ជំនឿដែលជឿថាវាជាច្បាប់* (*opinion juris*)[10]។ ការអនុវត្តរបស់រដ្ឋគួរតែជា "ការអនុវត្តដូចៗគ្នាដ៏ទូលំទូលាយ និងជាក់ស្តែងនៅក្នុងអត្ថន័យនៃបទបញ្ញត្តិដែលបានសម្អាងលើ"[11]។ ចំពោះ *ជំនឿដែលជឿថាវាជាច្បាប់* (*opinion juris*) តុលាការយុត្តិធម៌អន្តរជាតិបានសម្រេចថា រដ្ឋទាំងឡាយ "ត្រូវតែបានធ្វើសកម្មភាពដែលជាភស្តុតាងបង្ហាញអោយឃើញថាសកម្មភាពរបស់ខ្លួនធ្វើឡើងបណ្តាលមកពីជំនឿមួយ ដែលយល់ថាការអនុវត្តនេះគឺកាតព្វកិច្ចដែល

---

[9] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានបង្កើតឡើង "ក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់"។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១។ តួនាទីរបស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវបានដាក់ឱ្យអនុវត្តឱ្យពិតប្រាកដទៅនឹងរបៀបដែលច្បាប់នេះត្រូវបានបង្កើតឡើង រួមមានតាមរយៈការបញ្ជាក់ពីប្រធានបទ យុត្តាធិការផ្ទាល់ខ្លួននិងពេលវេលារបស់ អ.វ.ត.ក។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គ្រាន់តែបង្ហាញការកំណត់និយមន័យនៃការទទួលខុសត្រូវរបស់មេបញ្ជាការ លើអ្វីដែល អ.វ.ត.ក មានយុត្តាធិការតែប៉ុណ្ណោះ ប្រសិនបើវាមាននៅក្នុងច្បាប់កម្ពុជា។ វាមិនអាចបង្កើតច្បាប់ថ្មីដែលអាចអនុវត្តចំពោះព្រឹត្តិការណ៍ទាំងឡាយណា ដែលបានកើតឡើងក្នុងឆ្នាំ ១៩៧៥-១៩៧៩ ដោយគ្មានការបំពានលើគោលការណ៍ *nullum crimen sine lege* នោះទេ។ *សូមមើល ឧទាហរណ៍* សំណើទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, កថាខណ្ឌ១៥-១៦។

[10] សាស្ត្រាចារ្យ Fletcher & Ohlin ពន្យល់ថា "ច្បាប់ទំនៀមទម្លាប់ចាប់ផ្តើមជា ការអនុវត្តជាទម្លាប់ និងបន្ទាប់មកបានរីកដុះដាលទៅជាវិធានដែលចងកាតព្វកិច្ច នៅពេលដែលអ្នកដែលអនុវត្តតាមច្បាប់នេះចាប់ផ្តើមចាត់ទុកការអនុវត្តនេះជាច្បាប់ដែលចងកាតព្វកិច្ចចំពោះពួកគេ។" George P. Fletcher & Jens David Ohlin, *Reclaiming Fundamental Principles of Criminal Law in the Darfur Case*, 3 J. INT'L CRIM. JUST. ទំព័រ ៥៣៩, ៥៥៦ (២០០៥) ("Fletcher & Ohlin")។ ត្រូវកត់សម្គាល់ថា "ជាជាក់ស្តែងវាលំបាកក្នុងការបង្កើតឱ្យមានភាពស្របគ្នាគ្រប់គ្រាន់ ដើម្បីបញ្ជាក់សុពលភាពច្បាប់មួយថាជាច្បាប់ទម្លាប់អន្តរជាតិ"។ *ដូចដឹងទំព័រខាងលើ។ សូមមើល* បណ្តឹងឧទ្ធរណ៍ JCE, ឧបសម្ព័ន្ធ ក, ផ្នែកទី II ច សម្រាប់ការពិភាក្សាស៊ីជម្រៅនៃការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[11] *North Sea Continental Shelf Cases*, របាយការណ៍ ICJ (១៩៦៩), កថាខណ្ឌ ៧៤។

បង្កើតឡើងដោយវិធានច្បាប់ជាធរមានតម្រូវអោយធ្វើដូច្នេះ"[12]។ ចៅក្រម Robertson នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានពន្យល់ថា "គេគួរអនុវត្តដោយមិនចាំបាច់គរ៉ាំចំពោះចំណោទដែលចោទឡើងថា តើអំពើជាក់លាក់មួយអាចក្លាយជាបទល្មើសដែរឬទេ ហើយនៅពេលណានោះ គេគួរត្រូវតែញែកដោយប្រុងប្រយ័ត្ន ដើម្បីឱ្យវាដាច់ស្រឡះចេញពីចំណោទដែលចោទឡើងដែលថា តើអំពើនេះ*គួរ*ចាត់ទុក ឬត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ"[13]។

៦. ក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ការទទួលខុសត្រូវរបស់ថ្នាក់លើមិនមានឋានៈជាទម្លាប់អន្តរជាតិនោះទេព្រោះ៖ (១) ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងរឿងក្តីមួយចំនួនក្រោយសង្គ្រាមលោកលើកទី ២ មិនមានភាពគ្រប់គ្រាន់ដើម្បីអោយមានឋានៈជាទម្លាប់ (២) ការអនុវត្តរបស់រដ្ឋក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ មិនមានលក្ខណៈសាកល ឬដូចគ្នាបេះបិទដើម្បីបង្កើតនូវបទដ្ឋានទម្លាប់អន្តរជាតិមួយឡើយ និង (៣) ពិធីសារបន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលទាក់ទងនឹងការការពារជនរងគ្រោះពីជម្លោះប្រដាប់អាវុធអន្តរជាតិ ("ពិធីសារបន្ថែម I") មិនបានរៀបចំទម្លាប់អន្តរជាតិនេះឱ្យទៅជាច្បាប់នៅឡើយនៅក្នុងបរិបទនេះ[14]។

## ១. ច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី ២មិនបានកំណត់និយមន័យច្បាស់លាស់នូវធាតុផ្សំទាំងឡាយនៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ

៧. នៅពេលដែលមានគំនិតមួយដែលត្រូវបានលើកឡើងជាច្រើនសតវត្ស[15]ថា មេបញ្ជាការម្នាក់ត្រូវទទួលខុសត្រូវលើការបញ្ជាទៅលើទ័ពរបស់ខ្លួននោះ សាលាក្តីក្រោយសង្គ្រាមលោកលើកទី ២ គឺជា

[12] *រឿងក្តី Nicaragua តទល់នឹង United States*, (អង្គសេចក្តី), របាយការណ៍ ICJ ១៩៨៦, កថាខណ្ឌ ២០៧។

[13] *រឿងក្តីអ្នកអាជ្ញា តទល់នឹង Fofana & Kondewa*, SCSL-2004-14-AR72(E), សេចក្តីសម្រេចលើ ញត្តិបឋមសំអាងលើកង្វះខាតយុត្តាធិការ យោបល់ខ្វែងគ្នារបស់ របស់ចៅក្រម Robertson, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ ("យោបល់ខ្វែងគ្នារបស់ចៅក្រម Robertson"), កថាខណ្ឌ ៧។

[14] ពិធីសារបន្ថែមទី I និងទី II មិនអាចពឹងផ្អែកបាន ក្រៅពីសក្ខានុពលរបស់ខ្លួន ដើម្បីបង្ហាញច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ពិធីសារបន្ថែមទី I និងទី II ត្រូវបានឱ្យសច្ចាប័នដោយប្រទេសកម្ពុជា នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៨ តែប៉ុណ្ណោះ។

[15] *សូមមើល* Martinez. "អ្នកច្បាប់បានរៀបរាប់ពីទស្សនទានដែលថា មេបញ្ជាការយោធាទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ទាហានរបស់ខ្លួន យ៉ាងហោចណាស់ដូចទៅនឹងការសរសេររបស់ Sun Tzu ស្តីពីវិន័យកងទ័ពក្នុងឆ្នាំ ៥០០មុនគ្រិស្តសករាជ។ វាជាផ្នែកនៃការអនុវត្តផ្នែកយោធារបស់អឺរ៉ុបនៅក្នុងទស្សវត្សន៍ ១៤០០ ហើយវាមាននៅក្នុងមាត្រាផ្សេងៗរបស់អាមេរិកទាក់ទងនឹងសង្គ្រាម ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៧៧៦"។

សាលាក្ដីដំបូង ដែលភ្ជាប់ទស្សនាទាននៃការទទួលខុសត្រូវរបស់ថ្នាក់លើទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ[16]។ ទោះយ៉ាងនេះក៏ដោយ សាស្ត្រាចារ្យ Damaska បានពន្យល់ថា៖

> គេបានបើកមើលមួយសន្លឹកម្ដងៗដោយឥតប្រយោជន៍នូវសន្ធិសញ្ញាទាំងនេះ ដែលប្រឡាក់ដោយធូលីដី ដើម្បីរកការពន្យល់មួយដែលថា មេបញ្ជាការយោធាម្នាក់ត្រូវទទួលខុសត្រូវជាពិសេសចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលកូនទាហានរបស់ខ្លួនបានប្រព្រឹត្ត។ ខ្លឹមសារនៃសន្ធិសញ្ញាគ្មានអ្វីក្រៅពីនិយាយថា ថ្នាក់លើម្នាក់ដែលទ័ពរបស់ខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមគឺជាកម្មវត្ថុនៃការដាក់វិន័យ ឬការផ្ដន្ទាទោសព្រហ្មទណ្ឌ៖ ចារិកលក្ខណៈនៃខ្លឹមសារនេះនៅមិនទាន់បានកំណត់នៅឡើយ។ តាមពិតនៅចុងសម័យក្រោយសង្គ្រាមលោកលើកទី ២ ភ្លាមច្បាប់សន្ធិសញ្ញាបានកំហិតវិសាលភាពនៃទំនួលខុសត្រូវលើការបញ្ជារបស់ថ្នាក់លើទាំងអស់នោះ ទាំងជាជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមដោយបុគ្គលខ្លួនផ្ទាល់ ឬជាជនសមគំនិតនៅក្នុងរឿងនោះ ឬជាអ្នកបញ្ជាឲ្យគេប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះ[17]។

៨. ទោះបីជាការជំនុំជម្រះខ្លះក្រោយសង្គ្រាមលោកលើកទី ២ បានអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើជាទម្រង់នៃការទទួលខុសត្រូវមួយក៏ដោយ ក៏គ្មានអត្ថបទច្បាប់ណាមួយដែលបានបង្កើតសាលាក្ដីក្រោយសង្គ្រាមលោកលើកទី ២ រួមមានធម្មនុញ្ញនៃយោធាអន្តរជាតិ ("ធម្មនុញ្ញ IMT") ឬច្បាប់ស្ដីពីក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០ (Control Council Law No. 10) ឬធម្មនុញ្ញនៃសាលាក្ដី

---

[16] *សូមមើល* Kai Ambos, *ការទទួលខុសត្រូវរបស់ថ្នាក់លើ, នៅក្នុង* THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: A COMMENTARY, ក្បាល់ទី I ទំព័រ ៨២៣, ៨២៥ (បោះពុម្ពដោយ Oxford University Press, ២00២) ("Ambos, *ការទទួលខុសត្រូវរបស់ថ្នាក់លើ*")។ *ប៉ុន្តែសូមមើល* David Akerson & Natalie Knowlton, *The War on Terror and Its Implications for International Law & Policy: President Obama and the International Criminal Law Of Successor Liability*, 37 DENV. J. INT'L L. & POL'Y ទំព័រ ៦១៥, ៧0២-0៣ (២00៩)។ "នៅចុងសង្គ្រាមលោកលើកទី I, ការទទួលខុសត្រូវរបស់មេបញ្ជាកា ចំពោះការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មអំពើល្មើសច្បាប់ ត្រូវបានស្គាល់លើកដំបូងនៅក្នុងបរិបទអន្តរជាតិ ក្នុងរបាយការណ៍របស់គណៈកម្មការអន្តរជាតិស្ដីពីការទទួលខុសត្រូវរបស់ចារីនៃសង្គ្រាម និង ស្ដីពីការអនុវត្តការដាក់ទណ្ឌកម្ម។ របាយការណ៍នេះ ណែនាំឲ្យមានការបង្កើតតុលាការមួយក្នុងចំណោមរឿងផ្សេងទៀត ដើម្បីកាត់សេចក្ដីជនទាំងឡាយណាដែល 'បានបញ្ជា ឬ បានដឹងរឿងនោះ និង មានអំណាចធ្វើអន្តរាគមន៍ តែខកខានមិនបានទប់ស្កាត់ ឬ ចាត់វិធានការណ៍ទប់ស្កាត់ បញ្ចប់ឬបង្រ្កាបការរំលោភច្បាប់អន្តរជាតិ ឬ ទម្លាប់អន្តរជាតិ'។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍ទាំងនេះ មិនត្រូវបានអនុវត្តទេ ដោយសារមិនទាន់មានតុលាការអន្តរជាតិរហូតមកទល់ក្រោយសង្គ្រាមលោកលើកទី II"។

[17] Mirjan Damaska, *The Shadow Side of Command Responsibility*, 49 AM. J. COMP. L. ទំព័រ ៤៥៥, ៤៨៥ (២00១) ("Damaska")។

យោធាអន្តរជាតិសម្រាប់ចុងបូព៌ា (“ធម្មនុញ្ញ IMTFE”) បានចែងយ៉ាងពិតប្រាកដនូវបទបញ្ញត្តិទាំងឡាយដែលមានចែងពីទម្រង់នៃការទទួលខុសត្រូវនេះនោះទេ។ តាមពិត សហរដ្ឋអាមេរិកបានស្នើថា បទបញ្ញត្តិស្តីអំពីការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបញ្ចូលទៅក្នុងធម្មនុញ្ញ Nuremberg និងធម្មនុញ្ញ IMTFE[18]។ [ក៏ប៉ុន្តែ] សំណើនេះមិនបានប្រមូលនូវការគាំទ្រចំពោះលក្ខខណ្ឌតម្រូវឱ្យមានជាមុនដើម្បីបញ្ចូល [ទៅក្នុងធម្មនុញ្ញទាំងនេះ] នោះទេ។

៩. ការជំនុំជម្រះក្រោយសង្គ្រាមលោកលើកទី២ មិនសូវមានសារៈប្រយោជន៍ក្នុងការវាយតម្លៃអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងទម្លាប់អន្តរជាតិប៉ុន្មាននោះទេព្រោះ៖ សាលក្រមទាំងនោះខ្លីៗ ហើយប្រសិនបើមានសំអាងហេតុអង្គច្បាប់មែននោះ សំអាងហេតុអង្គច្បាប់ទាំងនោះក៏មិនមានពេញលេញដែរ។ រឿងក្តីទាំងអស់ក៏មិនស៊ីគ្នាផងដែរទាំងទងនឹងការតម្រូវឱ្យមានធាតុផ្សំអត្តនោម័ត (ឬ ចេតនាប្រព្រឹត្តបទល្មើស *mens rea*) ដើម្បីកំណត់ការទទួលខុសត្រូវនេះបាន។ ឧទាហរណ៍ នៅក្នុងរឿងក្តីដ៏ល្បីល្បាញមួយរបស់ *Yamashita* តុលាការហាក់បានអនុវត្តនូវបទដ្ឋានដ៏តឹងរ៉ឹងនៃការទទួលខុសត្រូវ[19] ចំណែកឯរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង* *Wilhelm List និងអ្នកផ្សេងទៀត* សាលាក្តីបានសម្រេចថា ថ្នាក់លើទទួលខុសត្រូវតែលើអំពើទាំងឡាយដែលគាត់បានដឹង ឬ “គួរបានដឹង” តែប៉ុណ្ណោះ”[20]។

១០. “ពេលខ្លះ និងគួរឱ្យសោកស្តាយ វាមានភាពខ្វះចន្លោះដ៏ធំធេង [ក្នុងរឿងក្តីទាំងនេះ] គឺថា សាលាក្តីបានសំដែងនូវទស្សនៈមិនស៊ីសង្វាក់គ្នាមួយចំនួន ចំពោះលក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័តក្នុងការសម្រាប់ការទទួលខុសត្រូវនៅក្នុងសេចក្តីសម្រេចតែមួយ។ តាមរយៈនេះ សាលាក្តីទាំងនេះបានជះឥទ្ធិពលក្រោយមកទៀតមកលើការភ័ន្តច្រឡំដ៏ច្រើន ដែលមានជាប់មកជាមួយទ្រឹស្តីនៅក្នុង

---

[18] Greg R. Vetter, *Command Responsibility of Non-Military Superiors in the International Criminal Court*, 25 YALE J. INT'L L. ទំព័រ ៨៩, ១០៥-០៦ (២០០០) (“Vetter”)។

[19] *សូមមើល* *Trial of General Tomoyuki Yamashita*, ដូចដែលបានបោះពុម្ពឡើងវិញក្នុង របាយការណ៍ច្បាប់នៃការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាម, ក្បាល់ទី IV (បោះពុម្ពដោយ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អង្គការសហប្រជាជាតិ, ឆ្នាំ ១៩៤៧) ទំព័រ ៣៥។

[20] *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Wilhelm List និងអ្នកផ្សេងទៀត*, ក្បាល់ទី XI, ការជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅចំពោះមុខតុលាការយោធា Nürnberg នៅក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ០១០។ “មេបញ្ជាការកងទ័ពត្រូវទទួលខុសត្រូវចំពោះអំពើរបស់មេបញ្ជាការក្រោមបង្គាប់របស់ខ្លួន ក្នុងការអនុវត្តបញ្ជារបស់គាត់ និង ចំពោះអំពើដែលមេបញ្ជាការកងទ័ពបានដឹង ឬគួរបានដឹងអំពីរឿងនោះ”។

តុលាការ ICTY និងតុលាការ ICTR"[21]។ ដោយសារកង្វះភាពច្បាស់លាស់បែបនេះ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ បានសម្រេចក្នុងឆ្នាំ ១៩៤៩ ថា "គោលការណ៍ទាំងឡាយសម្រាប់គ្រប់គ្រងប្រភេទនៃការទទួលខុសត្រូវនេះ... មិនទាន់បានឯកភាពនៅឡើយ"[22]។

១១. ក្រៅពីការមិនស៊ីសង្វាក់គ្នាទាក់ទងនឹងភាពអាចអនុវត្តបាននៃធាតុផ្សំអត្តនោម័ត រឿងក្ដីក្រោយនានាសង្គ្រាមលោកលើកទី ២ ដែលពិតជាបានអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ មិនអាចចាត់ទុកថា មានតម្លៃជាយុត្តិសាស្ត្រច្រើននោះទេ ពីព្រោះភាគច្រើននៃរឿងក្ដីទាំងនេះត្រូវបានគេរិះគន់ថាបានអនុវត្តទៅតាម "យុត្តិធម៌សម្រាប់អ្នកឈ្នះ"[23]។ ឧទាហរណ៍ ក្នុងរឿងក្ដី *Yamashita* សាស្ត្រាចារ្យ Ambos បានសរសេរថា "ទោះបីគេមិនយករឿងនេះមកគិតក៏ដោយ ដូចជាបដិសេធ

---

[21] Martinez. *សូមមើលផងដែរ* Curt Hessler, *Command Responsibility for War Crimes*, 82 Yale L.J. ទំព័រ ១២៧៤, ១២៨១ (១៩៧២-១៩៧៣) ("Hessler")។ "តុលាការក្រោយសង្គ្រាម មិនបានឈានទៅដល់ភាពស្របគ្នាក្នុងការបញ្ជាក់ពីធាតុផ្សំចេតនានៃការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ"។ *សូមមើល* ឧបសម្ព័ន្ធ សម្រាប់ការពិភាក្សា ពីរបៀបដែល *ធាតុផ្សំអត្តនោម័ត (mens rea)* ដែលត្រូវបានទាមទារដោយលក្ខន្តិកៈតុលាការ ICTY, ICTR និង SCSL ត្រូវបានអនុវត្តនៅតុលាការ *មិនអចិន្ត្រៃយ៍*។

[22] ដូចដែលបានដកស្រង់នៅក្នុង Ambos, *Superior Responsibility*, ទំព័រ ៨៣១។

[23] *សូមមើល* RICHARD H. MINEAR, VICTOR'S JUSTICE: THE TOKYO WAR CRIMES TRIAL 16 (១៩៧១)។ "[ខ]ណៈដែលសភាពបច្ចុប្បន្ននៃច្បាប់អន្តរជាតិមិនមានភាពច្បាស់លាស់ ឬ មិនគួរជាទីពេញចិត្ត - ឧទាហរណ៍ដូចជាទាក់ទងនឹងការទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះអំពើរបស់រដ្ឋ - ពេលនោះ មហាអំណាចទាំងបួន (the Big Four) បានចងក្រងច្បាប់អន្តរជាតិតាមវិធីដែលអំពើរបស់ អាល្លឺម៉ង់ និង ជប៉ុន គឺជាអំពើឧក្រិដ្ឋកម្ម ហើយមេដឹកនាំសត្រូវបុគ្គលត្រូវទទួលខុសត្រូវ"។ *សូមមើលផងដែរ* Damaska, នៅទំព័រ ៤៨៦-៨៧។ "វាមិនទាមទារឱ្យមានការសិក្សាស្រាវជ្រាវដ៏ស៊ីជម្រៅទៅលើសេចក្ដីសម្រេច ដែលបានចេញដោយតុលាការយោធាក្រោយសង្គ្រាមលោកលើកទី II ដើម្បីឱ្យដឹងថាពួកវាមិនមែនជាប្រភពជាក់ស្ដែងបំផុត ដែលគេនឹងរំពឹងថាអ្នកបង្កើតច្បាប់អន្តរជាតិទំនើប ទាញយកជាគំនិតនោះទេ។ រឿងដែលថាតុលាការនេះបានប្រឈមមុខនឹងជនដែលត្រូវបានចោទប្រកាន់ជាលក្ខណៈបុគ្គលដោយឧក្រិដ្ឋកម្មធ្ងន់ធ្ងរ មិនគួរធ្វើឱ្យយើងមើលមិនឃើញការពិតដែលថា បទដ្ឋានច្បាប់ដែលពួកគេបានបង្កើតឡើង (ជាពិសេសក្នុងចុងបូព៌ា) មិនមានភាពគ្រប់គ្រាន់ ចំពោះការយល់ដឹងបច្ចុប្បន្នរបស់យើងទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌជាមួយនឹងគោលបំណងមនុស្សធម៌នោះទេ។ ដូចដែលអ្នកប្រាជ្ញអន្តរជាតិដ៏ល្បីល្បាញម្នាក់បានកត់សម្គាល់យូរមកហើយថា បទដ្ឋានទាំងនេះដូចជា ជារឿយៗ "មានបំណងធ្វើឱ្យមេធាវីមានបំណងភ្លេចអ្វីៗទាំងអស់អំពីពួកវានៅពេលដើមដំបូងបង្អស់"។ លក្ខណៈទូទៅរបស់ពួកគេ ដែលទាក់ទងបំផុតនឹងគោលបំណងបច្ចុប្បន្ននេះ គឺភាពធ្ងន់ធ្ងរដែលមិនរងការប៉ះពាល់ ដែលអាចត្រូវបានចាត់ទុកយ៉ាងត្រឹមត្រូវថាជាប្រភពដ៏សំខាន់នៃការពង្រីកការទទួលខុសត្រូវ ដែលមាននៅក្នុងការទទួលខុសត្រូវរបស់មេបញ្ជាការដែលត្រូវបានចោទប្រកាន់"។ *សូមមើលផងដែរ* Hessler, ទំព័រ ១២៧៥។ " 'សេចក្ដីសម្រេច' ភាគច្រើនគឺជាការប៉ុនប៉ងធ្វើឡើងដោយវេទិការជំនុំជម្រះក្ដីដើម្បីត្រៀមការគាំទ្រផ្នែកច្បាប់ ខាងផ្លូវចិត្ត និងផ្នែកភស្តុតាង *ទាំងអស់*សម្រាប់សាលក្រមរបស់ខ្លួន"។

ចោលតម្លៃជាយុត្តិសាស្ត្រ*ណាមួយ*នៃសេចក្តីសម្រេចរឿងក្តី *Yamashita* ក៏គេត្រូវទទួលស្គាល់ថា កំហុសបច្ចេកទេសច្បាប់ចម្រុះរបស់ខ្លួន ដូចដែលបានទិះតៀនជាពិសេសនៅក្នុងមតិជំទាស់របស់ចៅក្រម Rutledge និងភាពលំអៀងនៃមនោគមវិជ្ជាជាតិសាសន៍ដូចដែលបានបង្ហាញថ្មីៗនេះដោយការសិក្សារបស់ Prévost បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តម្លៃអង្គច្បាប់ និងជាពិសេសតម្លៃសីលធម៌"[24]។

## ២. ការអនុវត្តរបស់រដ្ឋមិនបានបង្ហាញថាមានការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩

១២. រដ្ឋភាគច្រើនដូចជាប្រទេសកម្ពុជា[25]ជាដើមមិនមានបទបញ្ញត្តិ ដែលចែងពីការទទួលខុសត្រូវដ៏ជាក់លាក់របស់ថ្នាក់លើនៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួនក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩[26]នោះទេ។ ទោះបីជា

---

[24] Ambos, *Superior Responsibility,* ទំព័រ ៨២៧។ *សូមមើលផងដែរ* ការជំទាស់របស់ចៅក្រម Murphy នៅក្នុង *Yamashita,* ដូចដែលបានដកស្រង់ក្នុង Major William H. Parks, *Command Responsibility for War Crimes*, 62 MIL. L. REV. 1, ទំព័រ ៣៥ (១៩៧៣) (គូសបញ្ជាក់បន្ថែម)។ "គាត់មិនត្រូវបានចោទពីបទការចូលរួមផ្ទាល់ខ្លួនក្នុងអង្គហេតុនៃអំពើឃង់ឃ្នង ឬ ពីបទការបញ្ជាឬការលើកទោសឱ្យការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ពួកគេទាំងនោះទេ។ សូម្បីតែការមិនបានដឹងអំពីឧក្រិដ្ឋកម្មទាំងនេះ ក៏ត្រូវធ្លាក់ទៅលើរូបគាត់ដែរ។ វាគ្រាន់តែថា រូបគាត់បានមើលរំលងដោយខុសច្បាប់ ហើយខកខានមិនបានដកខ្លួនចេញពីតួនាទីរបស់គាត់ជាមេបញ្ជាការ គ្រប់គ្រងប្រតិបត្តិការរបស់សមាជិកក្រោមបង្គាប់របស់គាត់ ដោយអនុញ្ញាតិឱ្យពួកគេប្រព្រឹត្តអំពើឃង់ឃ្នងទាំងនោះ។ <u>ឯកសារដែលបានកត់ត្រាអំពីកិច្ចការសង្គ្រាម និង គោលការណ៍ច្បាប់អន្តរជាតិដែលបានបង្កើតឡើង ផ្តល់ឱ្យនូវច្បាប់ដ៏តិចតួចបំផុតសម្រាប់ការចោទប្រកាន់នេះ។"</u>

[25] *សូមមើល* ការពិភាក្សាក្រមព្រហ្មទណ្ឌ ១៩៥៦, *ដូចយោងខាងលើ*។

[26] សាស្ត្រាចារ្យ Damaska ពន្យល់ថា "<u>[បទបញ្ញត្តិការទទួលខុសត្រូវរបស់មេបញ្ជាការ នៃលក្ខន្តិកៈតុលាការ ICTY] ពង្រីកព្រំដែននៃការទទួលខុសត្រូវក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងវិសាលភាពហួសពីដែនកំណត់ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធច្បាប់ជាតិ</u>។ ថ្នាក់លើដែលមិនចាត់វិធានការណ៍ 'ចាំបាច់ និង សមហេតុផល' ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មរបស់ជនក្រោមបង្គាប់របស់គាត់ ឬ មិនដាក់ទណ្ឌកម្មពួកគេក្រោយពេលដែលពួកគេបានប្រព្រឹត្តអំពើនោះ អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ សូម្បីតែរូបគាត់មិនបាន 'រៀបផែនការណ៍ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬ ផ្សេងពីនេះ ជួយនិងជម្រុញ' សកម្មភាពឧក្រិដ្ឋនោះក៏ដោយ។ ដូច្នេះ មូលដ្ឋាននៃការទទួលខុសត្រូវក្រោមកថាខណ្ឌនេះមិនមែនជាការចូលរួមក្នុងលក្ខណៈជាក្រុមធម្មតានៃច្បាប់ក្រុងនោះទេ៖ ជាជាង ថ្នាក់លើត្រូវទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកក្រោមបង្គាប់ខ្លួនលើមូលហេតុតឹងតែងប្លែកជាងនេះ - ការខកខានមិនបានទប់ស្កាត់ និងការខកខានមិនបានដាក់ទណ្ឌកម្ម។ <u>ទាំងពីរនេះមានភាពស្មុកស្មាញ ដែលពិបាកសម្របសម្រួលជាមួយគោលការណ៍ដែលផ្តល់ព័ត៌មានដល់ច្បាប់ព្រហ្មទណ្ឌក្រុង។"</u> Damaska, ទំព័រ ៤៦១ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* មូលដ្ឋានទិន្នន័យអនុវត្តច្បាប់ជាតិ នៅលើគេហទំព័រតុលាការ

ច្បាប់ជាតិមានចែងពីបទបញ្ញត្តិបែបនេះក៏ដោយ ក៏បទបញ្ញត្តិទាំងនេះមិនមានលក្ខណៈសាកល គ្រប់គ្រាន់ដើម្បីធ្វើជាមូលដ្ឋាននៃការអនុវត្តជាទូទៅ និងស៊ីសង្វាក់គ្នារបស់រដ្ឋ និងដែលតម្រូវឱ្យរកឱ្យឃើញថាវាមាននៅក្នុងទម្លាប់អន្តរជាតិផងដែរ[27]។ យោងតាមសាស្ត្រាចារ្យ Bantekas បានឱ្យដឹងថា ក្រោយសង្គ្រាមលោកលើកទី ២ "គេមិនសូវប្រើប្រាស់ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើអស់រយៈពេលជាង ៣០ឆ្នាំ មកហើយ។ នៅក្នុងអំឡុងពេលនោះមានការយល់ដឹងអំពីផលប៉ះពាល់ផ្នែកនយោបាយទៅលើបទចោទប្រកាន់បែបនោះ ដែលធ្វើឱ្យប្រទេសទាំងអស់មានការអល់អែកធ្វើការដាក់ទោសទៅលើមន្ត្រីណាមួយ ចំពោះឧក្រិដ្ឋកម្មទាំងឡាយរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន...។ លើសពីនេះ ធាតុផ្សំអត្តនោម័តដ៏សមស្របមិនត្រូវបានសហគមន៍អន្តរជាតិព្រមព្រៀងជាឯកច្ឆ័ននៅឡើយ"[28]។

១៣. ក្រោយសង្គ្រាមលោកលើកទី ២ ការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបញ្ចូលបន្ថែមទៅក្នុងសៀវភៅណែនាំយោធារបស់ប្រទេសខ្លះ។ ឧទាហរណ៍ សៀវភៅណែនាំអំពីទ័ពជើងគោកសហរដ្ឋអាមេរិកស្តីពីច្បាប់ការធ្វើសង្គ្រាមឆ្នាំ ១៩៥៦ បានបញ្ជាក់ថា "មេបញ្ជាការយោធាអាចទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តដោយសមាជិកនៅក្រោមបង្គាប់នៃកងកម្លាំងប្រដាប់អាវុធ ឬ បុគ្គលដទៃដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ...។ មេបញ្ជាការ... ទទួលខុសត្រូវប្រសិនបើ<u>គាត់មានការដឹងលឺយ៉ាងពិតប្រាកដ ឬគួរមានការដឹងលឺ</u> តាមរយៈរបាយការណ៍ដែលគាត់បានទទួល ឬតាមមធ្យោបាយដទៃផ្សេងទៀតថា ទ័ពឬបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់បម្រុងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមមួយ ហើយគាត់បានខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របដើម្បីធានាឱ្យការប្រព្រឹត្តនោះអនុលោមទៅតាមច្បាប់សង្គ្រាម

---

ICC ដែលរៀបរាប់ឈ្មោះប្រទេសមួយចំនួនតូចដែលបច្ចុប្បន្ននេះមានការទទួលខុសត្រូវរបស់មេបញ្ជាការក្នុងការអនុវត្តច្បាប់។ *អាចមើលបាននៅ* http://iccdb.webfactional.com/data/keyword/569/។

[27] "និយមន័យ[ជា]តិ នៃឧក្រិដ្ឋកម្មអន្តរជាតិ ជារឿយៗរាប់បញ្ចូលមិនគ្រប់គ្រាន់ រាប់បញ្ចូលលើសពីតម្រូវការ ឬទាំងពីរ។ ... ភាពមិនស្របគ្នាដោយផ្នែកទាំងនេះក៏មានជាច្រើននៅក្នុងនិយមន័យជាតិនៃ ... លេខផ្សាយបន្ថែម ដូចជាការទទួលខុសត្រូវរបស់មេបញ្ជាការ។" WARD N. FERDINANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS ទំព័រ ១១៨-១៩ (ចេញផ្សាយដោយ T.M.C. Asser Press 2006)។

[28] Ilias Bantekas, *The Contemporary Law of Superior Responsibility*, 93 AM. J. INT'L L. ទំព័រ ៥៧៣, ៥៧៤-៧៥ (១៩៩៩) ("Bantekas")។

ឬក៏ធ្វើការដាក់ទណ្ឌកម្មទៅលើអ្នកដែលរំលោភលើច្បាប់សង្គ្រាមនោះ"[29]។

១៤. ទោះបីជាបទដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ មានចែងនៅក្នុងសៀវភៅណែនាំរបស់កងទ័ពជើងគោកក៏ដោយ ក៏តុលាការយោធាសហរដ្ឋអាមេរិកមិនបានអនុវត្តបទដ្ឋាននេះនៅពេលដែលធ្វើការជំនុំជម្រះរឿងក្តីរបស់អនុសេនីយ៍ឯក Ernest Medina ចំពោះការសម្លាប់រង្គាលជនជាតិ My Lai ដែលបានកើតឡើងនៅក្នុងសង្គ្រាមវៀតណាមនោះដែរ។ នៅក្នុងអំឡុងនៃសវនាការរបស់អនុសេនីយ៍ឯក Medina ក្នុងឆ្នាំ ១៩៧១ ចៅក្រមយោធាបានជម្រាបដល់គណៈវិនិច្ឆ័យថា ចំពោះការផ្តន្ទាទោសតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ ច្បាប់តម្រូវឱ្យមានការដឹងលឺដ៏ពិតប្រាកដ៖

> មេបញ្ជាការ[ម្នាក់]ត្រូវទទួលខុសត្រូវផងដែរ <u>ប្រសិនបើមេបញ្ជាការនោះមានការដឹងលឺដ៏ពិតប្រាកដ</u>ថា ទ័ពឬបុគ្គលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់កំពុងប្រព្រឹត្ត ឬរៀបនឹងប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមមួយ ហើយគាត់មានកំហុសដោយខកខានមិនបានចាត់វិធានការដ៏ចាំបាច់ និងសមស្របដើម្បីធានាថាការប្រព្រឹត្តបែបនោះគឺអនុលោមតាមច្បាប់សង្គ្រាម។ <u>អស់លោកនឹងពិនិត្យឃើញថា លក្ខខណ្ឌច្បាប់ទាំងអស់នេះដែលយកមកវិនិច្ឆ័យមេបញ្ជាការម្នាក់នេះតម្រូវឱ្យមានការយល់ដឹងដ៏ពិតប្រាកដ រួមទាំងការខកខានមិនបានបំពេញតួនាទីរបស់ខ្លួនដោយប្រពៃទៀតផង</u>[30]។

១៥. ភស្តុតាងបន្ថែមដែលបង្ហាញថា បទដ្ឋានខាងលើមានភាពមិនច្បាស់លាស់ ត្រូវបានរកឃើញនៅក្នុងអត្ថបទវិភាគច្បាប់យោធា ដែលសរសេរដោយវរៈសេនីយ៍ឯកកងទ័ពជើងគោកសហរដ្ឋអាមេរិក William Eckhardt នៅក្នុងឆ្នាំ ១៩៨២ ដែលមានចំណងជើងថា "ការទទួលខុសត្រូវព្រហ្មទណ្ឌ

---

[29] *ដូចដែលបានដកស្រង់ក្នុង រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត,* IT-47-01-PT, សេចក្តីសម្រេចលើការជំទាស់រួមគ្នាទៅនឹងយុត្តាធិការ, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ ៧៩ (គូសបញ្ជាក់បន្ថែម)។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋផ្សេងទៀត គ្រាន់តែរាប់បញ្ចូលបទប្បញ្ញត្តិទាំងនេះ ដែលនឹងដាក់ទណ្ឌកម្មមេបញ្ជាការចំពោះអំពើវិជ្ជមានរបស់ពួកគេ ជាជាងការលុបចោល។ ការណែនាំស្តីពីច្បាប់យោធាឆ្នាំ១៩៥៨របស់អង់គ្លេស (British Manual of Military Law) បានចម្លងការណែនាំអនុវត្តរបស់អាមេរិក (American Field Manual) ប៉ុន្តែបានដកចេញផ្នែកដែលដាក់ឱ្យថ្នាក់លើទទួលខុសត្រូវ នៅពេលពួកគេ "បានដឹងពិតប្រាកដ គួបានដឹង ..." *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៨០។ ដូច្នេះវាកំណត់ការទទួលខុសត្រូវចំពោះស្ថានភាពដែលអ្នកក្រោមបង្គាប់ បានប្រព្រឹត្តឧក្រិដ្ឋកម្ម តាមបញ្ជារបស់ថ្នាក់លើ។

[30] . ដូចដែលបានដកស្រង់ក្នុង Major James D. Levine II, *The Doctrine of Command Responsibility and its Application to Superior Civilian Leadership: Does the International Criminal Court have the Correct Standard?*, 193 MIL. L. REV. ទំព័រ៥២, ៦៦-៦៧ (២០០៧) (គូសបញ្ជាក់បន្ថែម)។

របស់ថ្នាក់លើ៖ សំណើសុំបទដ្ឋានដែលអាចអនុវត្តបាន”[31] (Command Criminal Responsibility: A Plea for a Workable Standard)។ លោកវរៈសេនីយ៍ឯក William Eckhardt បានពន្យល់ថា បទដ្ឋានសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើមានភាពមិនច្បាស់លាស់ ហើយថា ការដឹងលឺជាមុនរបស់មន្ត្រីម្នាក់ត្រូវតែកំណត់និយមន័យឱ្យបានត្រឹមត្រូវ[32]។ គាត់បានបញ្ជាក់ថា “ការពិនិត្យបទដ្ឋានដែលមាននៅពេលបច្ចុប្បន្ននេះ និងបទដ្ឋានថ្មីដែលត្រូវបានស្នើឡើងមកនេះបង្ហាញនូវគំនិតមិនឯកភាព និងមិនច្បាស់លាស់គួរឱ្យភ្ញាក់ផ្អើលដែលអាចបង្កគ្រោះថ្នាក់ដល់កិច្ចសន្យាសង្គមដែលជាមូលដ្ឋានធំបំផុតរវាងនាយទាហានម្នាក់ជាមួយនឹងពលរដ្ឋម្នាក់ ដែលគាត់ត្រូវផ្តល់នូវការបម្រើសេវាជូន”[33]។

១៦. ការលើកឡើងដែលថា មានភស្តុតាងបន្តិចបន្តួចដែលបង្ហាញថា រដ្ឋភាគច្រើនបានបញ្ចូលបទបញ្ញត្តិនៃការទទួលខុសត្រូវរបស់ថ្នាក់លើទៅក្នុងច្បាប់ជាតិរបស់ខ្លួនក្នុងឆ្នាំ ១៩៧៥-៧៩ និងថាមានភស្តុតាងដែលថា ធាតុផ្សំដែលតម្រូវសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើមិនត្រូវបានអនុវត្តស៊ីសង្វាក់គ្នានៅក្នុង និងរវាងរដ្ឋផ្សេងៗនោះ ការលើកឡើងបែបនេះបង្ហាញឱ្យឃើញថាការទទួលខុសត្រូវរបស់ថ្នាក់លើមិនមានចែងច្បាស់លាស់នៅក្នុងទម្លាប់អន្តរជាតិនោះទេ ទោះបីជាវាត្រូវបានអនុវត្តតាមវិធីណាក៏ដោយ។

**៣- ពិធីសារទី I បន្ថែម មិនបានចងក្រងឱ្យទៅជាក្រមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើការបញ្ជា**

១៧. ថ្វីបើមានការប្រើប្រាស់នូវការទទួលខុសត្រូវលើការបញ្ជាក្នុងនាមជារូបភាពមួយ បំណងដាក់ការទទួលខុសត្រូវនៅក្នុងសវនាការខ្លះក្រោយពីសង្គ្រាមលោកទីIIក៏ដោយ ក៏ទស្សនទាននេះពុំត្រូវបានចងក្រងឱ្យទៅជាច្បាប់នៅក្នុងសិទ្ធិសញ្ញាទីក្រុងហ្សឺណែវ(Geneva Conventions)ឆ្នាំ១៩៤៩ ទេ។ ពិធីសារបន្ថែមទី I នេះ បានចូលជាធរមាននៅថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៧៧។ មាត្រាទី ៨៦ និង ៨៧,[34] ដែលទាក់ទងជាមួយការទទួលខុសត្រូវលើការបញ្ជានៅក្នុងទំនាស់ប្រដាប់អាវុធអន្តរជាតិ

---

[31] Colonel William G. Eckhardt, *Command Criminal Responsibility: A Plea for a Workable Standard*, 97 MIL. L. REV. 1 (១៩៨២)។

[32] *ដូចដើងទំព័រខាងលើ។ សូមមើល* ជាពិសេសទំព័រ ១៨-២១។

[33] *ដូចជើងទំព័រខាងលើ* ទំព័រ១។

[34] មាត្រា ៨៦ ចែងថា, “ការខកខានមិនចាត់វិធានការណ៍ ១. រដ្ឋភាគី និង ភាគីជាប់នឹងទំនាស់ត្រូវទប់ស្កាត់ការរំលោភបំពានធ្ងន់ធ្ងរ និងចាត់វិធានការណ៍ចាំបាច់ដើម្បីទប់ស្កាត់ការរំលោភធ្ងន់ធ្ងរផ្សេងទៀត នៃអនុសញ្ញានេះ ឬ នៃពិធីសារនេះ

គឺជាការកត់សំគាល់ជាលើកទីមួយដែលការទទួលខុសត្រូវលើការបញ្ជានេះ ត្រូវបានចងក្រងជាក្រមនៅក្នុងច្បាប់អន្តរជាតិ ។

១៨. ពិធីសារបន្ថែមទី I ពុំអាចត្រូវបានពិចារណាសំរាប់យកទៅចងក្រងទៅជាក្រមច្បាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាព ដែលពេលហ្នឹងពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើកិច្ចបញ្ជាការ ដោយសារដឹងលឺដែលរកឃើញនៅក្នុងមាត្រា ៨៦ ត្រូវបានពង្រាងចុះឡើងៗប្រាំដងមុនពេលវាត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀត[35]។ ចំណុចនេះបានចង្អុលបង្ហាញថាអ្វីដែលត្រូវបានឯកភាពគ្នាជាចុងក្រោយបង្អស់នោះគឺ ផ្តែកទៅលើការចរចាគ្នានឹងការសំរបសំរួលគ្នារវាងបណ្តារដ្ឋ ហើយវាពុំចាំបាច់ឆ្លុះបញ្ចាំងទៅនឹងស្ថានភាពរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ ជាងនេះទៅទៀត នៅចុងឆ្នាំ ១៩៧៨ នៅពេលដែលរដ្ឋចំនួន៥៤ បានចុះហត្ថលេខាលើពិធីសារបន្ថែមទីI[36] គឺមានរដ្ឋតែ៣ ប៉ុណ្ណោះដែលបានផ្តល់សច្ចាប័នគឺ: ប្រទេស ឯលសល់វ៉ាដ័រ (El Salvador), ប្រទេស

---

ដែលជាលទ្ធផលមកពីការខកខានមិនបានចាត់វិធានការណ៍ នៅពេលដែលមានកាតព្វកិច្ចត្រូវធ្វើដូច្នេះ។

២. ការពិតដែលថា ការរំលោភលើអនុសញ្ញាទាំងនេះ ឬ ពិធីសារនេះ ត្រូវបានធ្វើឡើងដោយអ្នកក្រោមបង្គាប់ម្នាក់មិនធ្វើឱ្យរួចទោសពីភាពជាថ្នាក់លើរបស់ខ្លួន ពីការដាក់ទណ្ឌកម្ម ឬ ការទទួលខុសត្រូវផ្នែកវិន័យបានទេ ប្រសិនបើពួកគេបានដឹង ឬ មានព័ត៌មានដែលគួរផ្តល់លទ្ធភាពអាចឱ្យពួកគេចាត់វិធានការណ៍ក្នុងកាលៈទេសៈពេលនោះ ដូចដែលករណីនេះអាច ថាគាត់កំពុងបានប្រព្រឹត្ត ឬ ហៀបនឹងប្រព្រឹត្តការរំលោភបែបនោះ ហើយប្រសិនបើពួកគេមិនចាត់វិធានការណ៍ដែលអាចធ្វើបានក្នុងអំណាចរបស់ខ្លួនដើម្បីទប់ស្កាត់ ឬ បង្ក្រាបការរំលោភទាំងនោះទេ"។

មាត្រា ៨៧ ចែងថា "កាតព្វកិច្ចរបស់មេបញ្ជាការយោធា ១. រដ្ឋភាគី និងភាគីទាក់ទងនឹងទំនាស់ តម្រូវឱ្យមេបញ្ជាការយោធាទប់ស្កាត់ហើយបើសិនជាចាំបាច់បង្ក្រាប និង រាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចអំពីការរំលោភលើសន្ធិសញ្ញាទាំងនេះ និងការរំលោភលើលពិធីសារនេះ ចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធស្ថិតនៅក្រោមបញ្ជារបស់ខ្លួន និងជនទាំងឡាយណាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន។

២. ដើម្បីទប់ស្កាត់និងបង្ក្រាបការរំលោភបំពាន រដ្ឋភាគី និង ភាគីជាប់ទាក់ទងនឹងទំនាស់ត្រូវតម្រូវថា ប្រៀបធៀបជាមួយកម្រិតរបស់ពួកគេនៃការទទួលខុសត្រូវ មេបញ្ជាការធានាថាសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលស្ថិតនៅក្រោមបញ្ជារបស់ពួកគេ ដឹងពីកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងសន្ធិសញ្ញា និង ពិធីសារនេះ។

3. រដ្ឋភាគី និងភាគីទាក់ទងនឹងជំលោះត្រូវតម្រូវឱ្យមេបញ្ជាការណាដែលដឹងថា អ្នកក្រោមបង្គាប់ ឬ ជនផ្សេងទៀតដែលនៅក្រោមការត្រួតត្រារបស់ខ្លួន មានគម្រោងនឹងប្រព្រឹត្ត ឬ បានប្រព្រឹត្តការរំលោភលើសន្ធិសញ្ញា ឬ ពិធីសារនេះ ឱ្យផ្តួចផ្តើមវិធានការណ៍ចាំបាច់ដើម្បីទប់ស្កាត់ការរំលោភបំពានលើសន្ធិសញ្ញា ឬ ពិធីសារនេះ និងប្រសិនបើសមស្រប ត្រូវផ្តួចផ្តើមរៀបចំវិធានការណ៍ផ្នែកវិន័យ ឬ ផ្នែកព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នករំលោភបំពានលើសន្ធិសញ្ញានេះ។"

[35] *សូមមើល* Bantekas, ត្រង់ទំព័រ ៥៩១។

[36] *សូមមើល*បញ្ជីរឈ្មោះ ICRC នៃរដ្ឋភាគី *អាចមើលបាននៅ*http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P។

ហ្គាណា (Ghana), និងប្រទេសលីប៊ីយ៉ា(Libya)[37] ។ ប្រទេសជាច្រើន ថ្វីបើមិនទាំងអស់, ពុំបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី I នេះទេ រហូតមកទល់ពេលក្រោយទៀតទោះតាមវិធីណាក៏ដោយ[38]។ បើគិតពិចារណាលើសមាជិកអចិន្ត្រៃយ៍ទាំង៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិវិញគឺ ប្រទេសរុស្ស៊ីបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីIក្នុងឆ្នាំ១៩៨៩ ចក្រភពអង់គ្លេស ក្នុងឆ្នាំ ១៩៩៨, និងប្រទេសបារាំងក្នុងឆ្នាំ ២០០១[39]។ ប្រទេសចិន និង សហរដ្ឋអាមេរិកនៅពុំទាន់ផ្តល់សច្ចាប័នលើវានៅឡើយទេ[40]។ ចំណុចនេះពុំបានបង្ហាញឱ្យឃើញនូវការអនុវត្តន៍ជាទូលំទូលាយនិងស៊ីសង្វាក់គ្នារបស់រដ្ឋ ដែលជាការចាំបាច់សំរាប់បង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ <u>“មានហេតុផលសមរម្យមួយចំនួនដែលគេសង្ស័យទៅលើការសន្យាខ្លះ ដែលកាតព្វកិច្ចមិនត្រូវបានបំពេញ។ នេះក៏ព្រោះតែវិធានដែលគេអះអាងគឺមានតែសំបកក្រៅសំរាប់ឱ្យគេគោរពដោយសារវាមានន័យទូទៅពេក ឬ បើនិយាយឱ្យអាក្រក់ទៅទៀត គឺថាសេចក្តីថ្លែងរបស់វាគ្មានភាពស្មោះត្រង់”[41]។</u>

១៩. យោលទៅតាមសាស្ត្រាចារ្យ ម៉ាទីណេ (Martinez) “ពិធីសារបន្ថែមទី I នេះ បានធ្វើឱ្យពិបាកយល់ជាជាងបានបំភ្លឺអំពីលក្ខខណ្ឌតម្រូវនៃចេតនាប្រព្រឹត្តបទល្មើស (Mens rea)” របស់ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងច្បាប់អន្តរជាតិ[42]។ សូម្បីតែមាត្រា ៨៦ នៃពិធីសារបន្ថែមទី I ក៏ពុំអាចផ្តល់

---

[37] ផ្ទុយមកវិញ ក្នុងឆ្នាំ២០០១ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *Čelebići* បានពិចារណាមាត្រា ៨៧ នៃពិធីសារបន្ថែមI ដើម្បីឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារនៅចុងឆ្នាំ១៩៩២ មានរដ្ឋ១១៩បានឱ្យសច្ចាប័នវា។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Delalić និងអ្នកផ្សេងទៀត*, IT-96-21-A, សាលដីកាបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ (“សាលដីកាបណ្តឹងឧទ្ធរណ៍ *Čelebići*”), ជើងទំព័រ ២៥១។

[38] ការពិនិត្យឡើងវិញនៃកាលបរិច្ឆេទនៃការចូលជាសមាជិក ឬ ការឱ្យសន្ធាប័នបង្ហាញថា រដ្ឋភាគច្រើនបានឱ្យសច្ចាប័នពិធីសារបន្ថែម I នេះ នៅរវាងឆ្នាំ ១៩៨៥-១៩៩៥។ នៅចន្លោះឆ្នាំ ១៩៨៥ និង ១៩៩០ មានការឱ្យសច្ចាប័ន/ការចូលជាសមាជិកថ្មីចំនួន៤៥ និងនៅចន្លោះឆ្នាំ១៩៩០-១៩៩៥ មានការឱ្យសច្ចាប័ន/ការចូលរជាសមាជិកថ្មីចំនួន ៤៤។ *សូមមើល* បញ្ជីរ ICRC នៃរដ្ឋភាគី *អាចមើលបាននៅ* http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P ។

[39] *ដូចជើងទំព័រខាងលើ។*

[40] *ដូចជើងទំព័រខាងលើ។*

[41] Jens David Ohlin, *Applying the Death Penalty to Crimes of Genocide*, 99 Am. J. Int’l L. ទំព័រ៧៤៧, ៧៥២ (២០០៥)។ *សូមមើលផងដែរ* Fletcher & Ohlin, ត្រង់ទំព័រ ៥៥៧៖ “វាអាចយល់បានដែលថា មេដឹកនាំដែលជឿស៊ុបនៅលោកខាងលិច ... នឹងប្រកាស... ច្បាប់ដាច់ខាតនៃ CIL។ ជាសំណាងអាក្រក់នោះ ការជឿស៊ុប នៃលោកខាងលិចមិនអាចត្រូវបានពិចារណាឱ្យសមស្របថាជាប្រភពនៃច្បាប់នោះទេ”។

[42] Martinez។

នូវការនិយមន័យឲ្យស៊ីសង្វាក់គ្នាសំរាប់ពាក្យថាការទទួលខុសត្រូវលើការបញ្ជានេះដែរ។ បទអត្ថាធិប្បាយទៅលើពិធីសារបន្ថែមទី I នេះ បានកត់សំគាល់ថា នៅក្នុងមាត្រា ៨៦ អត្ថបទចុងក្រោយជាភាសាអង់គ្លេស និងបារាំង ក៏ហាក់ដូចជាឃ្លាតចាក់ន័យពីគ្នាចំពោះលក្ខខណ្ឌតម្រូវនៃចេតនាប្រព្រឹត្តបទល្មើស(*mens rea*) ក្នុងការទទួលខុសត្រូវរបស់ថ្នាក់លើ ។

ជាបឋមវាត្រូវបានកត់សំគាល់ឃើញថា មានភាពមិនស្របគ្នារវាងអត្ថបទភាសាអង់គ្លេសដែលសរសេរថា 'ព័ត៌មានដែលគួរតែបានជួយឲ្យគេបានសំរេចក្នុងការធ្វើការសន្និដ្ឋាន' និងភាសាបារាំង បានសរសេរថា 'des informations leur permettant de conclure' ដែលក្នុងនេះមានន័យថា 'ព័ត៌មានជួយគេឲ្យធ្វើការសន្និដ្ឋានបានសំរេច'។ ក្នុងករណីយ៉ាងដូច្នេះតាមច្បាប់គឺត្រូវយកមកប្រើនូវអត្ថន័យណា ដែលសម្របសម្រួលបានល្អបំផុតរវាងអត្ថបទពីរដែលមិនស្របគ្នានោះ ដោយយោលទៅតាមទិសដៅនិងគោលបំណងរបស់សន្ធិសញ្ញា។ ដូច្នេះអត្ថបទជាភាសាបារាំងគួរតែត្រូវផ្តល់អទិភាព ដោយសារវាក្តោបនូវអត្ថន័យទាំងពីរ[43]។

២០. ជាងនេះទៅទៀត ថ្វីបើ ពិធីសារបន្ថែមទី I នាពេលនេះត្រូវបានចាត់ទុកថាវាបង្កើតជាមូលដ្ឋានសំរាប់ការទទួលខុសត្រូវជាបុគ្គលរបស់របស់ថ្នាក់លើក៏ដោយ នៅពេលដែលពិធីសារនេះត្រូវបានព្រៀងឡើងកាលពីឆ្នាំ ១៩៧៧ គឺវាមានន័យដាក់កាតព្វកិច្ចទៅលើរដ្ឋ តែមិនមែនទៅលើបុគ្គលទេ[44]។ វា "បានបង្អាក់ការកំណត់ចរិតលក្ខណៈដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ ... បទប្បញ្ញត្តិទាំងឡាយរបស់វាបានចែងថា អ្នកដឹកនាំថ្នាក់លើដែលខកខានធ្វើការបង្ការ ឬ ទប់ស្កាត់នូវអំពើឧក្រិដ្ឋដែលប្រព្រឹត្តដោយថ្នាក់ក្រោមរបស់ខ្លួន នឹងមិនត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋទាំងនេះទេ។ ការកំណត់ដែលកាន់តែជាក់លាក់ថែមទៀតសំរាប់ការទទួលខុសត្រូវនេះ ដែលមាន

43 ពិធីសារបន្ថែមទៅនឹងសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការជាប់ទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារ I) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧, ការអត្ថាធិប្បាយ, កថាខណ្ឌ ៣៥៤៥។

44 *សូមមើល* Kai Ambos, *Joint Criminal Enterprise and Command Responsibility*, 5(1) J. INT'L CRIM. JUST. ទំព័រ ១, ៩ (២០០៧)។ "ទោះបីជា ច្បាប់ទាំងនេះបញ្ជាក់ទៅកាន់តែចំពោះរដ្ឋភាគី បច្ចុប្បន្ននេះពួកវាត្រូវបានចាត់ទុកជាមូលដ្ឋាននៃច្បាប់នៃការទទួលខុសត្រូវចំពោះការខកខានរបស់បុគ្គលក្នុងការចាត់វិធានការណ៍ ចាប់តាំងពីពេលដែលលទ្ធិនៃការទទួលខុសត្រូវរបស់ថ្នាក់លើនេះ និង ផ្នែកសំខាន់នៃអំពើល្មើសបានបង្កើតឡើងដោយ ច្បាប់ក្រុងហ្សឺណែវ (រួមទាំង AP I) ត្រូវបាន 'ធ្វើឲ្យទៅជាលក្ខណៈបុគ្គល' ដោយលក្ខន្តិកៈតុលាការ ICC និងដោយ ច្បាប់អនុវត្តជាតិ""។ (គូសបញ្ជាក់បន្ថែម)។

លក្ខណៈព្រហ្មទណ្ឌឬក៏ជាវិន័យ ផ្ទាល់ឬប្រយោលក្តី គឺត្រូវបានផ្តល់ទៅឲ្យច្បាប់ក្នុងប្រទេសដែលបានផ្តល់សច្ចាប័ន។"[45] ដូចដែលបានពន្យល់ដោយចៅក្រម រ៉ូប៊ឺតសុន (Robertson) រួចហើយថា ដើម្បីកំណត់ការទទួលខុសត្រូវបាន តុលាការព្រហ្មទណ្ឌមួយត្រូវតែ ទីមួយ៖ ចង្អុលបង្ហាញថា តើការហាមប្រាមចំពោះអំពើមួយចំនួនបានក្លាយជាវិធានមួយនៃច្បាប់អន្តរជាតិដែលចងកាតព្វកិច្ចដល់រដ្ឋដែរឬទេ នៅមុនពេល ទីពីរ៖ ធ្វើការចង្អុលបង្ហាញថា តើបទដ្ឋានរបស់ច្បាប់អន្តរជាតិបានប្រែរូបរាងទៅជាច្បាប់ព្រហ្មទណ្ឌហើយឬយ៉ាងណា ដើម្បីអោយការបំពានច្បាប់ ធ្វើអោយបុគ្គលនឹងអាចទទួលទណ្ឌកម្មបើសិនជាគេត្រូវបានកាត់ឲ្យជាប់ទោសដោយតុលាការ[46]។ នៅក្នុងរយៈវេលាពាក់ព័ន្ធនេះ ពិធីសារបន្ថែមទី I នេះគឺមានគោលបំណងសំរាប់ចងកាតព្វកិច្ចចំពោះរដ្ឋប៉ុណ្ណោះ។ ដូច្នេះលក្ខណៈវិនិច្ឆ័យទាំងនេះមិនត្រូវបានបំពេញទេ។

**គ- ទោះបីជា អវតក អាចអនុវត្តបាននូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយ ទោះបីជាការទទួលខុសត្រូវរបស់ថ្នាក់លើគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងពេលហ្នឹងក៏ដោយ ក៏គោលការណ៍និត្យានុកូលភាពមិនអនុញ្ញាតអោយមានការអនុវត្តន៍វានៅ អវតក ទេ**

២១. គោលការណ៍គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង *(nullum crimen, nulla poena sine lege)*[47] បានសង្កត់ថាគ្មានជនណាម្នាក់ត្រូវបានយកមកកាត់ទោសទេ ទាល់តែបទល្មើសនាពេលប្រព្រឹត្តនោះគឺជាអំពើដែលមានចែងនៅក្នុងច្បាប់ថាវាជាបទល្មើស ហើយវាទាល់តែការផ្តន្ទាទោសមានចែងដោយច្បាប់ ។ គោលការណ៍នេះគឺត្រូវបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (Universal Declaration of Human Rights) និងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋនិងនយោបាយ("ICCPR") ដែល អវតក ត្រូវតែគោរពបទដ្ឋានរបស់វាឲ្យបានពេញ

---

[45] Damaska, ត្រង់ទំព័រ ៤៨៦។

[46] យោបល់ខ្វែងគ្នារបស់ចៅក្រម Robertson, កថាខណ្ឌ ១២។

[47] ជាពិសេស គោលការណ៍ *nullum crimen sine lege* នៅក្នុងប្រទេសប្រកាន់ច្បាប់ស៊ីវិល ផ្តល់ទស្សនទានបួនគឺ៖ i) បទល្មើសព្រហ្មទណ្ឌ អាចត្រូវបានកំណត់ដោយច្បាប់ជាលាយលក្ខណ៍អក្សរ ("*nullum crimen sine lege scripta*")។ ii) បទល្មើសព្រហ្មទណ្ឌត្រូវតែកំណត់តាមរយៈច្បាប់ជាក់លាក់ ("*nullum crimen sine lege stricta*")។ iii) បទល្មើសព្រហ្មទណ្ឌត្រូវតែកំណត់មុនច្បាប់ចែង ("*nullum crimen sine proevia lege*")។ និង iv) បទល្មើសព្រហ្មទណ្ឌមិនត្រូវបកស្រាយដោយភាពស្រដៀងគ្នានោះទេ។ ANTONIO CASSESE, INTERNATIONAL CRIMINAL LAW ទំព័រ ១៤១-៤២ (បោះពុម្ពដោយ Oxford University Press 2003)។

លេញ។[48] គោលការណ៍នេះគឺជា "មូលដ្ឋានចំបងនៃនីតិរដ្ឋ ពីព្រោះវាបង្ខំឱ្យរដ្ឋាភិបាលទាំងឡាយ (នៅក្នុងករណីនៃច្បាប់ជាតិ) និងសហគមអន្តរជាតិ (នៅក្នុងករណីនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ) ឱ្យចាត់វិធានការជាវិជ្ជមានប្រឆាំងទៅនឹងឥរិយាបទសំដែងការស្អប់ខ្ពើម ឬ បើមិនដូច្នោះទេ ឥរិយាបទនេះនឹងមិនត្រូវបានទទួលទណ្ឌកម្មទេ ។ ហេតុដូច្នេះវាគឺផ្តល់ហេតុផលជាមូលដ្ឋានសំរាប់ការអោយមានច្បាប់ សន្ធិសញ្ញា និងអនុសញ្ញាទាំងឡាយ...។ នេះហើយគឺជាហេតុផលដែលយើងត្រូវបានគ្រប់គ្រងដោយច្បាប់ មិនមែនដោយប៉ូលីសនោះទេ"។[49] "វាអាចមិនមែនជាការងាយស្រួលទេ [ប៉ុន្តែ] វាច្បាស់លាស់ណាស់នៅពេលដែលអំពើទាំងឡាយជាអំពើសំដែងការស្អប់ខ្ពើម និងធ្វើឱ្យរន្ធត់ខ្លាំងនៅពេលដែលគោលការណ៍និត្យានុកូលភាព ត្រូវតែអនុវត្តឱ្យបានហ្មត់ចត់ដើម្បីធ្វើឱ្យប្រាកដថា ចុងចោទមិនត្រូវបានកាត់ឱ្យជាប់ទោសដោយសារតែការស្អប់ខ្ពើមឡើយ ប៉ុន្តែដោយសារមានភ័ស្តុតាង ឬមិនត្រូវជាប់ទោសដោយសារអំពើល្មើសដែលគ្មានអត្ថិភាពឡើយ។"[50]

២២. គោលការណ៍និត្យានុកូលភាពនៅក្នុងប្រទេសកម្ពុជាគឺតឹងរឹងជាងគោលការណ៍ ដែលបានរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UniversalDeclarationofHumanRights) និងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ICCPR)។ ច្បាប់កម្ពុជាតម្រូវថា ការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់កម្ពុជានៅក្នុងពេលដែលបទល្មើសដែលត្រូវបានចោទប្រកាន់នោះកើតមាន ដើម្បីឱ្យវាអាចអនុវត្តបាននៅក្នុង អវតក។ ចំណុចនេះគឺពីព្រោះយោងទៅតាមមាត្រាទី ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺថាគ្មានអំពើល្មើស

---

[48] យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដូចដែលត្រូវបានវិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ថា "[ព្រះ] រាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងមនុស្ស សិទ្ធិនារី និងសិទ្ធកុមារ។" (គូសបញ្ជាក់បន្ថែម)។ យោងតាមមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក, "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ " យោងតាមមាត្រា ១៣(១) នៃ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ "[សិ]ទ្ធិ របស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។"

[49] យោបល់ខ្វែងគ្នារបស់ចៅក្រម Robertson, កថាខណ្ឌ១៤ (គូសបញ្ជាក់បន្ថែម)។

[50] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២។

ណាអាចត្រូវទទួលទណ្ឌកម្មតាមរយៈការអនុវត្តន៍ការដាក់ទោស ដែលគ្មានបានប្រកាសដោយច្បាប់មុនពេលដែលអំពើនោះត្រូវបានប្រព្រឹត្តនោះទេ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ អាចគ្រាន់តែតម្រូវថាអំពើល្មើសមួយ (ឬ ទម្រង់នៃការទទួលខុសត្រូវមួយ) អាចមានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិនាពេលដែលបទល្មើសដែលត្រូវចោទប្រកាន់នោះកើតមាន ប៉ុន្តែ "គេត្រូវតែបង្ហាញពីលក្ខណៈខុសគ្នា រវាងលក្ខខណ្ឌតម្រូវជាមុននៃគោលការណ៍និត្យានុកូលភាពដែលត្រូវបានផ្តល់ន័យនៅក្នុងកំរិតអន្តរជាតិ ជាមួយនឹងគោលការណ៍និត្យានុកូលភាពនៃកំរិតច្បាប់ថ្នាក់ជាតិ។ ... មានប្រព័ន្ធច្បាប់ជាតិជាច្រើន ... តម្រូវឱ្យមានការអនុវត្តន៍តាមគោលការណ៍និត្យានុកូលភាពដ៏តឹងរឹង។"[51] ដូចដែលបានផ្តល់ឱ្យនៅក្នុងមាត្រា ៥ (២) នៃ ICCPR, នៅពេលដែលការគាំពារសិទ្ធិណាមួយនៅថ្នាក់ជាតិមានការទូលំទូលាយជាងថ្នាក់អន្តរជាតិ បទប្បញ្ញត្តិថ្នាក់ជាតិត្រូវតែគ្របដណ្តប់និងអនុវត្ត ។[52]

២៣. ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវតែអាយមើលឃើញជាមុន និងអាចស្វែងរកបាន នៅពេលដែលអំពើល្មើសដែលគេចោទថាបានប្រព្រឹត្ត ដើម្បីឱ្យត្រឹមត្រូវទៅតាមគោលការណ៍និត្យានុកូលភាព។ យោលទៅតាមអង្គជំនុំជម្រះសាលាដំបូងនៅ ICTY ក្នុងរឿងក្តី Vasiljevic ៖

> នៅពេលដែលអំពើខ្លះ ឬ អំពើមួយចំនួនមានលក្ខណៈត្រឹមត្រូវថាជាបទល្មើសនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះត្រូវតែពេញចិត្តខ្លួនឯងថាបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់ គឺបានផ្តល់អត្ថន័យច្បាស់លាស់គ្រប់គ្រាន់ *នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ*ស្តីអំពីសារធាតុទូទៅរបស់វា ចរិតលក្ខណៈព្រហ្មទណ្ឌរបស់វា និងភាពធ្ងន់ធ្ងររបស់វា ដែលអាចប្រមើលមើលឃើញជាមុន និងការស្វែងរកបាន។ នៅពេលធ្វើការវាយតំលៃនេះអង្គជំនុំជម្រះសាលាដំបូង ត្រូវពិចារណាលើចំណុចជាក់លាក់

---

[51] Helmut Kreicker, *National Prosecution of Genocide from a Comparative Perspective*, 5 INT'L CRIM. L. REV. ទំព័រ ៣១៣, ៣២០ (២០០៥) (គូសបញ្ជាក់បន្ថែម)។

[52] មាត្រា ៥(២) នៃ ICCPR ចែងថា "[មិន] ត្រូវធ្វើការរឹតត្បិត ឬធ្វើបដិប្បញ្ញត្តិណាមួយឡើយទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្សដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមានក្នុងរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា កតិកាសញ្ញានេះមិនទទួលស្គាល់សិទ្ធិទាំងនោះ ឬទទួលស្គាល់សិទ្ធិទាំងនោះក្នុងកម្រិតតិចជាង។" បទប្បញ្ញត្តិនេះរក្សាជាសំខាន់នូវភាពត្រឹមត្រូវនៃច្បាប់ណា ដែលផ្តល់ការការពារសម្រាប់សិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ កម្រិតខ្ពស់ជាងបទប្បញ្ញត្តិដែលចែងក្នុង ICCPR។ *សូមមើល* MANFRED NOVAK, UN COVENANT ON CIVIL AND POLITICAL RIGHTS: ICCPR COMMENTARY 118 (បោះពុម្ពដោយ N.P. Engel Publisher, 2005)។

00475547



របស់ច្បាប់អន្តរជាតិ ជាពិសេសលើចំណុចរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ តម្រូវការក្នុងការបំភ្លឺឱ្យបានគ្រប់គ្រាន់លើនិយមន័យនៃបទល្មើសព្រហ្មទណ្ឌ ការពិត គឺជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* *nullum crimen sine lege* ហើយវាត្រូវតែទទួលការវាយតំលៃតែនៅក្នុងបរិបទហ្នឹង។ បើសិនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំបានផ្តល់និយមន័យឱ្យបានច្បាស់លាស់គ្រប់គ្រាន់ចំពោះអំពើល្មើស ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈទេ អង្គជំនុំជម្រះសាលាដំបូងនឹងគ្មានជំរើសណាក្រៅពីត្រូវបង្ខំចិត្តមិនអនុវត្តយុត្តាធិការរបស់ខ្លួនលើអំពើល្មើសនោះ ដោយពុំចាំបាច់គិតដល់ថាអំពើល្មើសហ្នឹងគឺមានផ្តន្ទាទោសនៅក្នុងច្បាប់លក្ខន្តិកៈឡើយ។ ចំណុចនេះវាដូច្នេះ ព្រោះថា បើខ្ចីពាក្យពេចន៍ខ្លឹមសាររបស់តុលាការយោធារបស់សហរដ្ឋអាមេរិកនៅ Nuremberg មកប្រើ វាមានន័យថា អ្វីក៏ដោយដែលមាននៅក្នុងលក្ខន្តិកៈរបស់តុលាការដែលហួសពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកំពុងមានអត្ថិភាព គឺវាជាការប្រើប្រាស់អំណាច ដែលវាមិនមែនជាការប្រើប្រាស់ច្បាប់ទេ ។[53]

២៤. អង្គជំនុំជំរះបានពន្យល់បន្ថែមថា

ចេញពីទស្សនៈរបស់គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* *nullum crimen sine lege* វាគឺមិនអាចទទួលយកបានទាំងស្រុងទេ សំរាប់អង្គជំនុំជំរះសាលាដំបូងដែលកាត់ឱ្យជាប់ទោសចំពោះជនដែលជាប់ចោទណាម្នាក់ ដោយផ្អែកទៅលើមូលដ្ឋាននៃការហាមឃាត់មួយ បើពិចារណាលើភាពជាក់លាក់របស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងការអនុញ្ញាតសំរាប់ការបកស្រាយសើ១ស្តីពីវិធាននៃច្បាប់ព្រហ្មទណ្ឌ ដែលទាំងភាពច្បាស់លាស់មិនមានលក្ខណៈគ្រប់គ្រាន់សំរាប់កំណត់ការប្រព្រឹត្ត និងការញែកចេញពីគ្នារវាងអំពើល្មើស និងការអនុញ្ញាត ឬក៏ការស្វែងរកបានដែលពុំមានលក្ខណៈគ្រប់គ្រាន់ទៅតាមពេលវេលាដែលពាក់ព័ន្ធ ។ ការផ្តន្ទាទោសអំពើល្មើស ការពិត មិនគួរផ្អែកទៅលើបទដ្ឋានដែលជនជាប់ចោទពុំមានហេតុផលត្រូវដឹងនាពេលដែលអំពើនោះកើតមាន ហើយបទដ្ឋាននេះត្រូវតែធ្វើឱ្យបានច្បាស់លាស់គ្រប់គ្រាន់ចំពោះថាតើអំពើអ្វី ឬ ការខកខានណាខ្លះដែល

---

[53] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Vasiljević*, IT-98-32-T, សាលក្រម, ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ ២០១-០២ (គូសបញ្ជាក់បន្ថែម)។

អាចរាប់បញ្ចូលទៅនឹងការទទួលខុសត្រូវលើអំពើល្មើសរបស់គាត់ ។[54]

២៥. សូម្បីតែការទទួលខុសត្រូវរបស់ថ្នាក់លើ អាចត្រូវបានចាត់ទុកថាជាផ្នែកមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-៧៩ ក្តី វាពុំត្រូវបានផ្តល់អត្ថន័យច្បាស់លាស់គ្រប់គ្រាន់ទេទៅលើការទទួលខុសត្រូវដែលមើលឃើញជាមុនចំពោះជនត្រូវចោទឡើយ ។ នេះគឺច្បាស់លាស់ណាស់នៅក្នុងកិច្ចសន្ទនាដែលលើកពីខាងដើម *(supra)* ពាក់ព័ន្ធទៅនឹងការខ្វះខាតនូវការបំភ្លឺដែលទាក់ទងទៅភាពចាំបាច់របស់ *mens rea* ឬក៏ការអនុវត្តន៍របស់វាទៅលើជម្លោះផ្ទៃក្នុង និងទៅអ្នកដឹកនាំខាងផ្នែកស៊ីវិល។[55] សាស្ត្រាចារ្យ ម៉ាទីណេ (Martinez) បានធ្វើការសង្ខេបថាភាពមិនស្របគ្នាទាំងឡាយដែលធ្វើបង្ហាញនូវរូបភាពនៃការទទួលខុសត្រូវនេះ គឺពុំបានបង្កើតឱ្យមានភាពស្របគ្នា និងភាពច្បាស់លាស់បានគ្រប់គ្រាន់ទេ ដើម្បីបង្កើតជាមាត្រដ្ឋានមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖

> នៅពេលផ្សេងៗគ្នា សាលាក្តី និងតុលាការអន្តរជាតិបានកាត់ឱ្យជាប់ទោសអ្នកដឹកនាំដោយផ្អែកទៅលើស្ថានភាពផ្លូវចិត្តរបស់ជនទាំងនោះ ដែលស្ថានភាពនេះត្រូវបានរៀបរាប់សំដៅទៅលើចំណេះដឹង, ការធ្វេសប្រហែស, ការព្រងើយកន្តើយ និងប្រហែលជាផ្អែកទៅលើការទទួលខុសត្រូវយ៉ាងតឹងរឹង។ នៅក្នុងករណីខ្លះគេបានអនុវត្តបទដ្ឋានអត្តនោម័តសំរាប់

[54] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ១៩៣ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Hadžihasanović *និងអ្នកផ្សេងទៀត,* IT-01-47-PT, "បណ្តឹងឧទ្ធរណ៍បន្ទាន់បន្តិ ស្តីពីការជំទាស់រួមគ្នាទៅនឹងយុត្តាធិការ, ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ១៥។ "វាត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិថា គោលការណ៍នៃភាពស្របច្បាប់តម្រូវថា បទឧក្រិដ្ឋដែលត្រូវបានចោទត្រូវ បង្ហាញក្នុងច្បាប់មួយដែលអាចមើលបាន និងថាវាអាចព្យាករណ៍ជាមុនបានថាអំពើនោះអាចត្រូវដាក់ទណ្ឌកម្មជាអំពើឧក្រិដ្ឋ នៅពេលដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើង"។

[55] សរសេរក្នុងឆ្នាំ២០០២ សាស្ត្រាចារ្យ Ambos កត់សម្គាល់ថា "ជាសរុប ការរិះគន់របស់ UNWCC ក្នុងឆ្នាំ ១៩៤៩ថា 'គោលការគ្របដណ្តប់លើប្រភេទនៃការទទួលខុសត្រូវ ... មិនត្រូវបានដោះស្រាយនៅឡើយ' មិនបានបាត់បង់សុពលភាពរបស់ខ្លួនទាំងស្រុងនោះទេ ជាពិសេសនោះទាក់ទងនឹងបញ្ហាច្បាប់ព្រហ្មទណ្ឌមាននៅក្នុងលទ្ធិនេះ។ ទោះបីជាការអនុវត្តលទ្ធិនេះមានការកើនឡើង ចាប់តាំងពីសង្គ្រាមលោកលើកទី២មក ធាតុផ្សំរបស់វាមិនទាន់ត្រូវបានកំណត់ឱ្យបានច្បាស់លាស់គ្រាប់គ្រាន់ដើម្បីឱ្យអស់មន្ទិលសង្ស័យនោះទេ ទាក់ទងនឹងគោលការណ៍ *nullum crimen* ដូចដែលមានចែងក្នុងលក្ខន្តិកៈក្រុងរ៉ូម (មាត្រា ២២, ២៤) ជាពិសេសនោះជាមួយនឹងតម្រូវការរបស់វាចំពោះភាពពិតប្រាកដនិងតឹងតែងតាមផ្លូវច្បាប់"។ Ambos, *Superior Responsibility,* ត្រង់ទំព័រ ៨៤៧។ *សូមមើលផងដែរ* van Schaak, ត្រង់ទំព័រ ១៦៦។ ""វា ... ពិបាកទទួលយកថា ធាតុផ្សំត្រឹមត្រូវនៃឧក្រិដ្ឋកម្មអាចត្រូវបានប្រមូលយកមកពី (នៅពេល) ការប្រព្រឹត្តផ្ទុយគ្នានៃរបស់រដ្ឋជាដៃគូជាច្រើនជាមួយនឹងអាកប្បកិរិយាផ្លូវចិត្តទៅនឹងការអនុវត្តជាក់លាក់"។

វិនិច្ឆ័យស្ថានភាពផ្លូវចិត្ត ប៉ុន្តែនៅពេលផ្សេងគេហាក់ដូចជាអនុវត្តបទដ្ឋានសត្យានុម័ត។ គេបានប្រឹងប្រែង ដោយពុំបានជោគជ័យជាធំដុំទេដើម្បីធ្វើឱ្យជ្រួតជ្រាបនូវ 'ឆន្ទៈងងឹតងងុល' ទៅក្នុងចំណុចមួយមិនច្បាស់លាស់ក្នុងចន្លោះអ្វីដែលហៅថាជា ការដឹងលឺ និងអ្វីជាការព្រងើយកន្តើយ ។ គេជានិច្ចជាកាលគេពុំដែលច្បាស់លាស់ទេក្នុងការបញ្ជាក់ថាតើស្ថានភាពផ្លូវចិត្តវាតម្រូវដូចគ្នាឬយ៉ាងណា ពាក់ព័ន្ធទៅនឹងធាតុផ្សំសំភារៈនិមួយៗនៃអំពើល្មើសដែលត្រូវបានប្រព្រឹត្តដោយពួកអ្នកក្រោមបង្គាប់។ ហើយគេបានធ្វើយ៉ាងដូច្នេះជាច្រើនភាសា ដោយប្រើប្រាស់ពាក្យស័ព្ទផ្សេងៗដែលពុំអាចបកប្រែឱ្យបានចំល្អពីភាសាមួយទៅភាសាមួយទៀត និងពីប្រព័ន្ធច្បាប់មួយទៅប្រព័ន្ធច្បាប់មួយទៀត ។ លទ្ធផលចុងក្រោយគឺថា ថ្វីបើមានករណីច្បាប់នាគន្លងសតវត្សហើយក៏ដោយ ក៏វានៅតែមានលំបាកក្នុងការធ្វើការអត្ថាធិប្បាយឱ្យបានច្បាស់លាស់អំពីធាតុផ្សំអត្តនោម័ត សំរាប់ការទទួលខុសត្រូវរបស់។[56]

២៦. វាក៏ដូចជាមិនទំនងផងដែរ ចំពោះករណីយុត្តិសាស្ត្រដែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវក្នុងទម្រង់បែបនេះ ដែលជនដែលត្រូវចោទអាចស្វែងរកបានក្នុងពេលពាក់ព័ន្ធ។ មានអត្ថបទមួយដែលបានសរសេរនៅក្នុងឆ្នាំ ១៩៧២ ហើយត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីច្បាប់របស់សាកលវិទ្យាល័យយ៉េល (Yale Law Journal) បានពន្យល់ថា ដោយសារសេចក្តីសំរេចរបស់ IMTFE ដែលមានរួមបញ្ចូលយោបល់ជំទាស់ និង ការយល់ស្រប "កម្រមាន សូម្បីតែនៅក្នុងបណ្ណាល័យរបស់សកលវិទ្យាល័យធំៗរបស់ [សហរដ្ឋអាមេរិក] ក៏ដោយ" ហើយផ្ទុយទៅវិញអត្ថបទនេះយោងឯកសារបន្ទាប់បន្សំ ដែលដកស្រង់ ឬ រៀបពាក្យពេចន៍ឡើងវិញទៅលើសាច់រឿងជាប្រយោលនៃសាលក្រម ។[57] បើសិនជាសាលក្រមនេះវាកម្រមានសំរាប់អ្នកសិក្សារបស់សហរដ្ឋអាមេរិកទៅហើយ ធ្វើម៉េចសាលក្រមនេះនិងសេចក្តីសំរេចដទៃទៀតរបស់សាលាក្តីនានាបន្ទាប់ពីសង្គ្រាមលោក

---

[56] Jenny S. Martinez, *Understanding* Mens Rea *in Command Responsibility: From Yamashita to Blaškić and Beyond*, 53 J. INT'L CRIM. JUST.ទំព័រ៦៣៨ (២00៧) ("Martinez")។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ៖* "ទាំងច្បាប់សន្ធិសញ្ញាអន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបានកំណត់និយមន័យទូលំទូលាយដែលអាចទទួលយកបានជាសកលនៃសភាពនៃចិត្តដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិនោះទេ ហើយការប៉ុនប៉ងណាមួយដើម្បីស្វែងរកគោលការណ៍រួមនៃច្បាប់ដែលស្របទៅនឹងប្រព័ន្ធច្បាប់ជាតិ មានភាពស្មុកស្មាញដោយវិធីសាស្ត្រផ្សេងៗដែលប្រព័ន្ធនោះជ្រើសរើសយក។ ជាអកុសល្យ សេចក្តីសម្រេចចិត្តជាអន្តរជាតិមិនតែងតែ ដឹងដោយខ្លួនឯងអំពីភាពខុសគ្នាក្នុងផ្នែកវាក្យស័ព្ទនោះទេ ហើយពួកវាក៏មិនច្បាស់លាស់អំពីគំនិតដែលវាក្យស័ព្ទនោះប៉ុនប៉ងក្រសោបយកនោះដែរ"។

[57] Hessler, ជើងទំព័រ១០។

លើកទីពីរអាចនឹងស្វែងរកបានដោយជនដែលត្រូវចោទនៅក្នុងប្រទេសកម្ពុជា?

២៧. អវតក អាចនឹងមិនអនុវត្តករណីការទទួលខុសត្រូវលើរបស់ថ្នាក់លើក្នុងឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ដោយគ្រាន់តែវាត្រូវបានគេប្រើប្រាស់នៅសាលាក្តីពិសេស *ad hoc* ឡើយ។ សាលាក្តីបែបនេះមិនដែលគោរពគោលការណ៍ *nullum crimen sine lege* បានទៀងទាត់ទេ។

> ក្នុងអំឡុងពេលការកើតឡើងវិញនៃ [ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ] ក្រោយពេលសង្គ្រាមត្រជាក់ តុលាការព្រហ្មទណ្ឌជាតិ និងអន្តរជាតិ បានឈានទៅបង្កើតនិងធ្វើទំនើបភាវូបនីយកម្មនូវច្បាប់ដែលកើតក្នុងរយៈកាលសង្គ្រាមលោកលើកទីពីរ។ នៅក្នុងដំណើរការនេះ តុលាការទាំងឡាយបានព្យាយាមអនុវត្តន៍នូវបទដ្ឋាន [ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ] ថ្មីទៅលើការប្រព្រឹត្តពីអតីតកាល។ <u>ចំណុចនេះគឺមិនមែនការអនុវត្តន៍សមរម្យនូវអ្វីមួយដែលបង្កើតដោយតុលាការទៅលើលិខិតដែលមានជាធរមានទេ។ ផ្ទុយទៅវិញ សាលាក្តីទាំងនេះកំពុងឈោងចាប់យកការកែប្រែមុខមាត់ថ្មីនៃ [ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ] យ៉ាងពេញទំហឹងតាមរយៈយុត្តិសាស្ត្រ ដែលឆ្លើយតបទៅនឹងយុត្តាធិការរបស់ខ្លួន ជាតួរូបបទល្មើសអន្តរជាតិ ហើយនិងទម្រង់ផ្សេងៗនៃការទទួលខុសត្រូវដែលអាចអនុវត្តបាន</u> ។ ស្របពេលគ្នានោះ តុលាការទាំងឡាយកំពុងធ្វើបច្ចុប្បន្នភាព និង កំពុងពង្រីកនូវសន្ធិសញ្ញាប្រវត្តិសាស្ត្រផ្សេងៗ ការហាមឃាត់ជាទំនៀមទំលាប់ កំពុងធ្វើអោយខកចិត្តចំពោះការរៀបចំនានាដែលបានចរចារដោយហ្មត់ចត់រវាងបណ្តារដ្ឋ កំពុងបដិសេធចោលនូវការសំរបសំរួលខាងផ្លូវនយោបាយ ដែលបានធ្វើឡើងដោយបណ្តារដ្ឋក្នុងរយៈពេលសន្និបាតពហុភាគី ហើយកំពុងធ្វើការបន្ថែមខ្លឹមសារទៅក្នុងបទប្បញ្ញត្តិ ដែលសរសេរមិនច្បាស់លាស់ ដែលបង្កើតឱ្យមានកាន់តែច្រើននូវការថ្កោលទោសជារបៀបប្រតិសកម្ម លើអំពើអាក្រក់ពីអតីតកាលជាជាងការអនុវត្តន៍ក្រមព្រហ្មទណ្ឌពិស្តាសំរាប់អនាគត។[58]

អវតក មិនត្រូវធ្លាក់ចូលក្នុងអន្ទាក់ដូចគ្នានេះទេ តែត្រូវគោរពនូវ គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* *nullum crimen sine lege* ដើម្បីឱ្យស្របទៅតាមច្បាប់កម្ពុជា។

## IV. សេចក្តីសន្និដ្ឋាន និងសំណើសុំការបន្ធូរបន្ថយ

---

[58] Beth van Schaack, *Crimen Sine Lege: Judicial Lawmaking at the Intersection of Law and Morals*, 97 GEO. L.J. ទំព័រ១១៩, ១២៣-២៤ (២០០៨)។ (គូសបញ្ជាក់បន្ថែម) ("van Schaack")។

ឯកសារ: D 345/2

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

២៨. ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ នឹងរំលោភ*គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង* *nullum crimen sine lege* ។ ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនជាផ្នែកមួយនៃច្បាប់កម្ពុជាទេ និងមិនមានចែងក្នុងទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែរ ។

**ហេតុដូច្នេះហើយ** ដូចហេតុផលទាំងអស់ដែលមានថ្លែងខាងលើ ក្រុមមេធាវីការពារក្ដី ស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេតមេត្តា ច្រានចោលការដាក់អនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្ដីគោរព។

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក អៀង សារី

ចុះហត្ថលេខា ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៥** ខែកុម្ភៈ ឆ្នាំ **២០១០**